ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ:** *របាយការណ៍នៃកិច្ចប្រជុំរវាង DICO និង IAs ប្រចាំខែឧសភា*

**យោង:** *លិខិតអញ្ជើញលេខ ១៧៨០ ពណ-សហអ ចុះថ្ងៃទី ១១ ឧសភា ២០១១*

*តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព និង រាយការណ៍ ជូន* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបថា: កាលពីថ្ងៃទី ១៩ ឧសភា ២០១១ DICO បានរៀបចំកិច្ចប្រជុំប្រចាំខែជាមួយ ភ្នាក់ងារអនុវត្តគម្រោង IAs (Implementing Agencies) ដើម្បីជុំរុញការអនុវត្តន៍គម្រោង TDSP ។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូននូវចំណុចសំខាន់ៗដូចខាងក្រោម:*

ក)- *របាយការណ៍វឌ្ឍនៈភាពរបស់គម្រោង TDSP*

- *ផ្នែកហិរញ្ញវត្ថុ (Finance)៖ នៅក្នុងត្រីមាសទី១ ឆ្នាំ ២០១១ យើងបានធ្វើការចំណាយ US$230,680 នៅក្នុងផែនការ(ត្រីមាស) US$356,911 (=64.6%)*
- *ផ្នែកលទ្ធកម្ម (Procurement)៖ គិតមកត្រឹមថ្ងៃទី ១៨ ឧសភា ២០១១ យើងសម្រេចបាន 17% នៃចំនួនសរុបរបស់មូលនិធិទាំងមូល*
- *រហូតមកទល់ពេលនេះ មាន MoU ចំនួន ១៦ ត្រូវបានចុះហត្ថលេខា ជាមួយ IAs ចំនួន ១២ ។ មាន MoU ចំនួន ០៣ ទៀតដែលយើងកំពង់រៀបចំ ហើយនឹងចុះហត្ថលេខាក្នុងពេលឆាប់ៗ*
- *ផ្សព្វផ្សាយអំពីកាលបរិច្ឆេទនៃកិច្ចប្រជុំប្រចាំឆ្នាំរបស់ SSC-TD-TRI, IC, និង DICO and IAs meeting (ដូចមានភ្ជាប់នៅក្នុង Presentation Slides)*

- ប្រគល់ភារៈកិច្ចឲ្យមន្ត្រី LO (Liaison Official) របស់ DICO ទទួលបន្ទុកប្រចាំ IAs នីមួយៗ
- វឌ្ឍនៈភាពក្នុងការអនុវត្តន៍ Benchmarks របស់ធនាគារពិភពលោក (សូមពិនិត្យក្នុង Presentation Slides)

ខ)- ការផ្សព្វផ្សាយអំពី M&E

DICO បានផ្សព្វផ្សាយអំពីការងារ M&E (សូមពិនិត្យ ក្នុង Presentation Slides)

គ)- ការផ្សព្វផ្សាយអំពីការគ្រប់គ្រងហិរញ្ញវត្ថុ

ផ្នែកហិរញ្ញវត្ថុរបស់ DICO បានធ្វើការផ្សព្វផ្សាយ និងណែនាំដល់ IAs ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងមានដូចខាងក្រោម:

- ការទូទាត់ និងសំណើសុំបំពេញបេឡាសាច់ប្រាក់
- សំណើសុំទូទាត់ចំណាយជូនទីប្រឹក្សាជាតិ និងអន្តរជាតិ
- ការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់វគ្គបណ្តុះបណ្តាល, សិក្ខាសាលា, និងដំណើរទស្សនៈកិច្ចសិក្សាក្នុងនិងក្រៅប្រទេស
- រាល់ការចំណាយទាំងអស់ត្រូវមាននៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ឧសភា ២០១១

**ប្រធាននាយកដ្ឋាន**

**ឈៀង ពេជ្រ**